**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការខេត្ត
សៀមរាប-ឧត្តរមានជ័យ
សាលក្រម
លេខ ១២ "ខ" ចុះថ្ងៃទី ០៧
ខែ មីនា ឆ្នាំ ២០០៦
សំណុំរឿងរដ្ឋប្បវេណី
លេខ ៤៧ ចុះថ្ងៃទី ០៧
ខែ កុម្ភៈ ឆ្នាំ ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅទីតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នាថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៦ ដោយមានសមាសភាព :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ប្រធានតុលាការខេត្ត

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្ត

ដើម្បីជំនុំជំរះសំណុំរឿងក្តីរដ្ឋប្បវេណីលេខ ៤៧ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដែលមានកម្មវត្ថុបណ្តឹង : **ប្តឹងសុំលែងលះប្រពន្ធ , ប្តឹងសុំសិទ្ធិគ្រប់គ្រងកូន** ។

រវាងដើមចោទឈ្មោះ ម ម ភេទប្រុស អាយុ ៣៦ ឆ្នាំ មុខរបរធ្វើជាទាហាន ទីលំនៅ១ភូមិតាកុះ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ។ ឪពុកឈ្មោះ អ ម (ស) ម្តាយឈ្មោះ ទ ជ (រ) ប្រពន្ធឈ្មោះ ឆ អ មានកូន ០៤នាក់ ។

និងចុងចម្លើយឈ្មោះ ឆ អ ភេទស្រី អាយុ ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរមេផ្ទះ ទីលំនៅ១ភូមិស្រះស្រង់ខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ អ ឆ (ស) ម្តាយឈ្មោះ ឡ ម ប្តីឈ្មោះ ម ម មានកូន ០៤នាក់ ។

**ដំណើររឿងមានដូចតទៅ :**

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ដើមចោទឈ្មោះ ម ម បានប្តឹងសុំលែងលះប្រពន្ធឈ្មោះ ឆ អ ដោយមូលហេតុការរស់នៅមិនចុះសំរុងនឹងគ្នា ហើយរយៈពេល ០២ឆ្នាំហើយ ដែលប្រពន្ធខ្លួនបានចុះចោលធ្វើអោយខ្លួនមិនអាចស៊ូទ្រាំរស់នៅជាប្តីប្រពន្ធតទៅទៀតបាន ។ ខ្លួនអស់មនោសញ្ចេតនាពីប្រពន្ធហើយ ។ ទ្រព្យសម្បត្តិរួមគ្មានអ្វីទេ ។ បំណុលរួមមានជំពាក់ឈ្មោះ ។

១-ភឿន យ៉ង ចំនួន ២០០ដុល្លា និង ០៣ជី " ពីររយដុល្លាសហរដ្ឋអាមេរិក និង បីជីមាស " ។

សាលក្រមនេះចូលជាស្ថាពរចាប់ពីថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៦
ដោយគ្មានគូភាគីណាចូលមកប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។
សៀមរាប.ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦
ក្រឡាបញ្ជី
ហត្ថលេខា និង ត្រា
[redacted]

CamScanner

២-ភឿន យ៉ឹង  ចំនួន ៤០ ដុល្លា " សែសិបដុល្លាសហរដ្ឋអាមេរិក "
៣-ឡាច ធី  ចំនួន ០៣ជី " បីជី " មាស
៤-ធន់ បូ  ចំនួន ០៥ជី " ប្រាំជី " មាស
៥-ម៉ុយ មុំ  ចំនួន ១២០ដុល្លា " មួយរយម្ភៃដុល្លាសហរដ្ឋអាមេរិក "
៦-ភឿន យុក  ចំនួន ១០០ដុល្លា " មួយរយដុល្លាសហរដ្ឋអាមេរិក "

## នាពេលសវនាការ

ដើមចោទឈ្មោះ ម ម បានឆ្លើយថា ខ្លួនប្ដឹងសុំលែងលះប្រពន្ធឈ្មោះ ឆ អ ដោយមូលហេតុការរស់នៅមិនចុះសំរុងគ្នារយៈពេល ០២ឆ្នាំហើយ ដែលខ្លួនបានបែកលំនៅដ្ឋានពីគ្នាធ្វើអោយខ្លួនមិនអាចស៊ូទ្រាំរស់នៅជាប្ដីប្រពន្ធតទៅទៀតបានទេ ។ ខ្លួនអស់មនោសញ្ចេតនាពីប្រពន្ធហើយ ។

កូន ០៤នាក់គឺ :

កូនទី ១ ឈ្មោះ ម សអ ភេទស្រី អាយុ ១២ឆ្នាំ កំពុងនៅរៀន
កូនទី ២ ឈ្មោះ ម សអ ភេទស្រី អាយុ ១០ឆ្នាំ កំពុងនៅរៀន
កូនទី ៣ ឈ្មោះ ម សគ ភេទស្រី អាយុ ០៨ឆ្នាំ កំពុងនៅរៀន
កូនទី ៤ ឈ្មោះ ម ម ភេទប្រុស អាយុ ០៤ឆ្នាំ កំពុងនៅរៀន

ចំពោះកូនទាំង ០៤នាក់នេះ ខ្លួនសុខចិត្តប្រគល់អោយចុងចម្លើយឈ្មោះ ឆ អ គ្រប់គ្រង ។

អាហារកិច្ចចិញ្ចឹមកូនទាំង ០៤នាក់ ខ្លួនសុខចិត្តប្រគល់ដីមួយកន្លែងស្ថិតនៅភូមិស្រះស្រង់ខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប មានទំហំ ៥០ម គុណនឹង ៧០ ម ដែលមានព្រំប្រទល់ខាងជើងទល់ដី ម ជ ខាងត្បូង ទល់ដីមិនចាំឈ្មោះ ខាងកើតទល់ដី ឈ ម ខាងលិចទល់ដី ឆ ម "ជាដីអប្បរា" អោយចុងចម្លើយឈ្មោះ ឆ អ ទុកលក់ចិញ្ចឹមកូនចុះ ។

ទ្រព្យសម្បត្តិរួមគ្មានទេ ។ ទ្រព្យសម្បត្តិផ្ទាល់ខ្លួនមានមុនរៀបការ គឺខ្លួនមានដីចំនួន ០២កន្លែងស្ថិតនៅភូមិស្រះស្រង់ខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប ទាំងអស់គឺមួយកន្លែងមានទំហំ ៥០ម គុណនឹង ៧០ម ដែលមានព្រំប្រទល់ខាងជើងទល់ដី ម ជ ខាងត្បូងទល់ដីមិនចាំឈ្មោះ ខាងកើតទល់ ឈ ម ខាងលិចទល់ ឆ ម " ជាដីអប្បរា " និង មួយកន្លែងទៀតមានទំហំ ២០ម គុណ ១០០ម ដែលមានព្រំប្រទល់ខាងជើងទល់ផ្លូវស្រះស្រង់ ខាងត្បូងទល់ដី ម ជ ខាងកើតទល់ ឈ ម ខាងលិចទល់ដី ម ជ " ជាដីអប្បរា " ។ បំណុលរួមមានជំពាក់ :

១-ភឿន យ៉ង  ចំនួន ២០០ដុល្លា និង ០៣ជី " ពីររយដុល្លាសហរដ្ឋអាមេរិក និង បីជីមាស "
២-ភឿន យ៉ឹង  ចំនួន ៤០ដុល្លា " សែសិបដុល្លាសហរដ្ឋអាមេរិក "
៣-ឡាច ធី  ចំនួន ០៣ជី " បីជី " មាស
៤-ធន់ បូ  ចំនួន ០៥ជី " ប្រាំជី " មាស
៥-ម៉ុយ មុំ  ចំនួន ១២០ដុល្លា " មួយរយម្ភៃដុល្លាសហរដ្ឋអាមេរិក "
៦-ភឿន យុក  ចំនួន ១០០ដុល្លា " មួយរយដុល្លាសហរដ្ឋអាមេរិក "

ចំពោះបំណុលទាំងអស់នេះ ខ្លួនសុខចិត្តប្រគល់ដីមួយកន្លែង ស្ថិតនៅភូមិស្រះស្រង់ខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប មានទំហំ ២០ម គុណនឹង ១០០ម ដែលមានព្រំប្រទល់ ខាងជើងទល់ផ្លូវស្រះស្រង់

CamScanner

ខាងត្បូងទល់ដី ម ជ ខាងកើតទល់ ឈ ហ ខាងលិចទល់ដី ម ជ "ជាដីអប្បរា" អោយចុងចម្លើយឈ្មោះ ឆ អ ទុកសងបំណុលគេចុះ ខ្លួនសុំយករួចតែខ្លួន ។

ចុងចម្លើយឈ្មោះ ឆ អ បានឆ្លើយថា ខ្លួនក៏ព្រមលែងលះដើមចោទដែរ ដោយមូលហេតុការរស់នៅមិនចុះសំរុងនឹងគ្នា ហើយខ្លួនពិតជាបានចុះចោលដើមចោទរយៈពេល ០២ឆ្នាំពិតមែន ឥឡូវខ្លួនអស់មនោសញ្ចេតនាពីដើមចោទឈ្មោះ ម ម ហើយខ្លួនមិនអាចស៊ូទ្រាំរស់នៅជាប្តីប្រពន្ធតទៅទៀតបានទេ ។

កូន ០៤នាក់គឺ :

កូនទី ១ ឈ្មោះ ម សអ ភេទស្រី អាយុ ១២ឆ្នាំ កំពុងនៅរៀន

កូនទី ២ ឈ្មោះ ម សអ ភេទស្រី អាយុ ១០ឆ្នាំ កំពុងនៅរៀន

កូនទី ៣ ឈ្មោះ ម សគ ភេទស្រី អាយុ ០៨ឆ្នាំ កំពុងនៅរៀន

កូនទី ៤ ឈ្មោះ ម ម ភេទប្រុស អាយុ ០៤ឆ្នាំ កំពុងនៅរៀន

ចំពោះកូនទាំង ០៤នាក់នេះខ្លួនសុំសិទ្ធិគ្រប់គ្រង ។ ហើយខ្លួនសុខចិត្តទទួលដីមួយកន្លែងស្ថិតនៅភូមិស្រះស្រង់ខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប ដែលមានទំហំ ៥០ម គុណនឹង ៧០ម ដែលមានព្រំប្រទល់ខាងជើងទល់ដី ម ជ ខាងត្បូងទល់ដីមិនចាំឈ្មោះ ខាងកើតទល់ ឈ ហ ខាងលិចទល់ ឆ ហ "ជាដី អប្បរា" និង មួយកន្លែងទៀតមានទំហំ ២០ម គុណ ១០០ម ដែលមានព្រំប្រទល់ ខាងជើងទល់ផ្លូវស្រះស្រង់ ខាងត្បូងទល់ដី ម ជ ខាងកើតទល់ ឈ ហ ខាងលិចទល់ដី ម ជ "ជាដីអប្បរា" ពីដើមចោទឈ្មោះ ម ម ដើម្បីទុកលក់ចិញ្ចឹមកូនចុះ ។

ទ្រព្យសម្បត្តិរួមគ្មានអ្វីទេ ។ ទ្រព្យសម្បត្តិផ្ទាល់របស់ដើមចោទឈ្មោះ ម ម មុនរៀបការ គឺខ្លួនមានដីចំនួន ០២កន្លែង ស្ថិតនៅភូមិស្រះស្រង់ខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាបទាំងអស់ គឺមួយកន្លែងមានទំហំ ៥០ម គុណនឹង ៧០ម ដែលមានព្រំប្រទល់ខាងជើងទល់ដី ម ជ ខាងត្បូងទល់ដី មិនចាំឈ្មោះខាងកើតទល់ ឈ ហ ខាងលិចទល់ ឆ ហ "ជាដីអប្បរា" និង មួយកន្លែងទៀតមានទំហំ ២០ម គុណ ១០០ម ដែលមានព្រំប្រទល់ខាងជើងទល់ផ្លូវស្រះស្រង់ ខាងត្បូងទល់ដី ម ជ ខាងកើតទល់ ឈ ហ ខាងលិចទល់ដី ម ជ "ជាដីអប្បរា" ពិតប្រាកដមែន ។

ទ្រព្យសម្បត្តិផ្ទាល់របស់ខ្លួនមានមុនរៀបការ គឺខ្លួនមានដី ០១កន្លែងស្ថិតនៅភូមិស្រះស្រង់ខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប មានទំហំ ៤០ម គុណនឹង ៤០ម ដែលមានព្រំប្រទល់ខាងជើងទល់ដី ឆ អ ខាងត្បូងទល់ដី ឋ ក ខាងកើតទល់ ត យ ខាងលិចទល់ ច រ "ជាដីអប្បរា" ខ្លួនសុំសិទ្ធិគ្រប់គ្រងជាកម្មសិទ្ធិ ។

បំណុលរួមមានជំពាក់ឈ្មោះ :

១-ភឿន យ៉ង ចំនួន ២០០ដុល្លា និង ០៣ជី "ពីររយដុល្លាសហរដ្ឋអាមេរិក និង បីជីមាស"

២-ភឿន យ៉ឹង ចំនួន ៤០ដុល្លា "សែសិបដុល្លាសហរដ្ឋអាមេរិក"

៣-ឡាច ធី ចំនួន ០៣ជី "បីជី" មាស

៤-ធន់ បូ ចំនួន ០៥ជី "ប្រាំជី" មាស

៥-ម៉យ មុំ ចំនួន ១២០ដុល្លា "មួយរយម្ភៃដុល្លាសហរដ្ឋអាមេរិក"

៦-ភឿន យុក ចំនួន ១០០ដុល្លា "មួយរយដុល្លាសហរដ្ឋអាមេរិក"

ចំពោះបំណុលទាំងអស់នេះខ្លួនធានាចេញសងតែម្នាក់ឯង ហើយខ្លួនសុខចិត្តទទួលដីមួយកន្លែងស្ថិតនៅភូមិស្រះស្រង់ខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប មានទំហំ ២០ម គុណនឹង ១០០ម ដែលមានព្រំ

CS CamScanner

ប្រទល់ខាងជើងទល់ផ្លូវស្រះស្រង់ ខាងត្បូងទល់ដី ម ជ ខាងកើតទល់ ឈ ហ ខាងលិចទល់ដី ម ជ " ជាដីអប្បរា" ពីដើមចោទឈ្មោះ ម ម ដើម្បីទុកលក់សងបំណុលរួមទាំងអស់ចុះ ។

## តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា

រឿងនេះជារឿងរដ្ឋប្បវេណី ដែលជាប្រភេទរឿងអាពាហ៍ពិពាហ៍ និង គ្រួសារ ដោយគោលបំណងអាពាហ៍ពិពាហ៍លែងបានសំរេច ហើយមានសភាពធ្ងន់ធ្ងរភាគីទាំងពីរពុំអាចរួមរស់នៅជាមួយគ្នាតទៅទៀតបាន ព្រោះដើមចោទ និង ចុងចម្លើយអស់មនោសញ្ចេតនាពីគ្នាហើយ ។ ទោះបីមានការលែងលះគ្នាក៏ដោយភាគីទាំងពីរមិនទុកគ្នាជាសត្រូវ ហើយឪពុកម្តាយត្រូវមានកាតព្វកិច្ច អប់រំ ចិញ្ចឹមកូន តាមច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។ ហេតុនេះសូមតុលាការពិចារណាសំរេចតាមច្បាប់ចុះ ។

-បានស្តាប់ដើមចោទឆ្លើយអោយការណ៍ និង ប្តឹងសុំ

-បានស្តាប់ចម្លើយចុងចម្លើយឆ្លើយដោះសារ

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ
## យល់ឃើញថា

-ពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-គូស្វាមីភរិយានេះបានគ្នាជាប្តីប្រពន្ធមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។

-ដើមចោទប្តឹងសុំលែងលះចុងចម្លើយ ហើយចុងចម្លើយព្រមព្រៀងដែរនោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-ដើមចោទសុខចិត្តប្រគល់សិទ្ធិគ្រប់គ្រងកូន ០៤នាក់គឺ :

កូនទី១ ឈ្មោះ ម សអ ភេទស្រី អាយុ ១២ឆ្នាំ កំពុងនៅរៀន

កូនទី២ ឈ្មោះ ម សអ ភេទស្រី អាយុ ១០ឆ្នាំ កំពុងនៅរៀន

កូនទី៣ ឈ្មោះ ម សគ ភេទស្រី អាយុ ០៨ឆ្នាំ កំពុងនៅរៀន

កូនទី៤ ឈ្មោះ ម ម ភេទប្រុស អាយុ ០៤ឆ្នាំ កំពុងនៅរៀន

អោយចុងចម្លើយឈ្មោះ ឆ អ ហើយចុងចម្លើយឈ្មោះ ឆ អ ក៏បានព្រមព្រៀងដែរនោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-ចុងចម្លើយប្តឹងសុំទាមទារអាហារកិច្ចចិញ្ចឹមកូនទាំង ០៤នាក់ សរុបចំនួន ៣.០០០ដុល្លា " ប៉ាន់ដុល្លាសហរដ្ឋ " ហើយដើមចោទឈ្មោះ ម ម សុខចិត្តប្រគល់ដីមួយកន្លែង ស្ថិតនៅភូមិស្រះស្រង់ខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប មានទំហំ ៥០ម គុណនឹង ៧០ម ដែលមានព្រំប្រទល់ខាងជើង ទល់ដី ម ជ ខាងត្បូងទល់ដីមិនចាំឈ្មោះ ខាងកើតទល់ដី ឈ ហ ខាងលិចទល់ដី ឆ ហ "ជាដីអប្បរា" អោយចុងចម្លើយឈ្មោះ ឆ អ ទុកលក់យកប្រាក់អាហារកិច្ចចិញ្ចឹមកូន ហើយចុងចម្លើយឈ្មោះ ឆ អ ព្រមព្រៀងដែរនោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

CS CamScanner

-ទ្រព្យសម្បត្តិរួមគ្មានអ្វីពាក់ព័ន្ធគ្នាទេ តុលាការមិនពិចារណាដល់បញ្ហានេះ ។

-ដីមួយកន្លែងស្ថិតនៅភូមិស្រះស្រង់ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប មានទំហំ ៤០ម គុណនឹង ៤០ម ដែលមានព្រំប្រទល់ខាងជើងទល់ដី ឆ អ ខាងត្បូងទល់ដី ៨ ក ខាងកើតទល់ ត យ ខាងលិចទល់ ច រ "ជាដីអប្បរា" ជាទ្រព្យសម្បត្តិផ្ទាល់របស់ចុងចម្លើយឈ្មោះ ឆ អ មានមុនរៀបការជាមួយឈ្មោះ ម ម ចុងចម្លើយឈ្មោះ ឆ អ សុំសិទ្ធិគ្រប់គ្រងជាកម្មសិទ្ធិ ហើយដើមចោទឈ្មោះ ម ម យល់ព្រមដែរនោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-បំណុលរួមមានជំពាក់ឈ្មោះ :

១-ភឿន យ៉ង ចំនួន ២០០ដុល្លា និង ០៣ជី " ពីររយដុល្លាសហរដ្ឋអាមេរិក និង បីជីមាស " .

២-ភឿន យ៉ឹង ចំនួន ៤០ដុល្លា " សែសិបដុល្លាសហរដ្ឋអាមេរិក "

៣-ឡាច ធី ចំនួន ០៣ជី " បីជី " មាស

៤-ធន់ បូ ចំនួន ០៥ជី " ប្រាំជី " មាស

៥-ម៉យ មុំ ចំនួន ១២០ដុល្លា " មួយរយម្ភៃដុល្លាសហរដ្ឋអាមេរិក "

៦-ភឿន យុក ចំនួន ១០០ដុល្លា " មួយរយដុល្លាសហរដ្ឋអាមេរិក "

-ចំពោះបំណុលទាំងអស់នេះចុងចម្លើយឈ្មោះ ឆ អ ធានាចេញសងតែម្នាក់ឯង ហើយដើមចោទព្រមប្រគល់ដីមួយកន្លែង ស្ថិតនៅភូមិស្រះស្រង់ខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប មានទំហំ ២០ម គុណនឹង ១០០ម ដែលមានព្រំប្រទល់ខាងជើងទល់ផ្លូវស្រះស្រង់ ខាងត្បូងទល់ដី ម ជ ខាងកើតទល់ ឈ ហ ខាងលិចទល់ដី ម ជ "ជាដីអប្បរា" អោយចុងចម្លើយ ដើម្បីទុកលក់សងបំណុលរួមទាំងអស់ ហើយចុងចម្លើយព្រមព្រៀងដែរនោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-គោលដៅនៃអាពាហ៍ពិពាហ៍ពុំអាចសំរេចបានឡើយ ដោយដើមចោទ និង ចុងចម្លើយអស់មនោសញ្ចេតនាពីគ្នាហើយ ។

## ហេតុដូច្នេះទើបវិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-សំរេចឱ្យឈ្មោះ ម ម និង អ្នកស្រី ឆ អ លែងលះគ្នាចាប់ពីថ្ងៃនេះតទៅ ។ ដាក់កំហុសលើប្តី ។

៣-សំរេចឱ្យអ្នកស្រី ឆ អ ស្ថិតនៅភាពជាមេម៉ាយចំនួន ៣០០ថ្ងៃគិតចាប់ពីថ្ងៃនេះតទៅ ។

៤-កូន ០៤នាក់គឺ :

កូនទី១ ឈ្មោះ ម សអ ភេទស្រី អាយុ ១២ឆ្នាំ កំពុងនៅរៀន

កូនទី២ ឈ្មោះ ម សអ ភេទស្រី អាយុ ១០ឆ្នាំ កំពុងនៅរៀន

កូនទី៣ ឈ្មោះ ម សគ ភេទស្រី អាយុ ០៨ឆ្នាំ កំពុងនៅរៀន

កូនទី៤ ឈ្មោះ ម ម ភេទប្រុស អាយុ ០៤ឆ្នាំ កំពុងនៅរៀន

ត្រូវប្រគល់អោយទៅអ្នកស្រី ឆ អ គ្រប់គ្រងតាមការព្រមព្រៀងរបស់គូភាគី ។ ហើយឈ្មោះ ម ម ត្រូវជួយចិញ្ចឹមកូនតាមលទ្ធភាពដែលខ្លួនមាន ។

មាតាបិតាត្រូវមានសិទ្ធិ និង ករណីយកិច្ចអប់រំ ថែរក្សាចិញ្ចឹមកូនតាមមាត្រា ៧៤ នៃច្បាប់អាពាហ៍

CamScanner

ពិពាហ៍ និង គ្រួសារ ។

៥-សំរេចប្រគល់ដីមួយកន្លែង ស្ថិតនៅភូមិស្រះស្រង់ខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប មានទំហំ ៥០ម គុណនឹង ៧០ម ជាទ្រព្យផ្ទាល់ខ្លួនរបស់ ម ម ដែលមានព្រំប្រទល់ខាងជើងទល់ដី ម ៩ ខាងត្បូងទល់ដីមិនចាំឈ្មោះ ខាងកើតទល់ដី ឈ ហ ខាងលិចទល់ដី ឆ ហ "ជាដីអប្បរា" អោយចុងចម្លើយឈ្មោះ ឆ អ ទុកលក់យកប្រាក់អាហារកិច្ចចិញ្ចឹមកូន តាមការព្រមព្រៀងរបស់គូភាគី ។

៦-ទុកសិទ្ធិអោយដើមចោទឈ្មោះ ម ម ទៅសួរសុខទុក្ខដល់កូនបាន ។

៧-បំណុលរួមមានជំពាក់ឈ្មោះ :

ក-ភឿន យ៉ង ចំនួន ២០០ ដុល្លា និង ០៣ជី "ពីររយដុល្លាសហរដ្ឋអាមេរិក និង បីជីមាស"

ខ-ភឿន យ៉ឹង ចំនួន ៤០ ដុល្លា "សែសិបដុល្លាសហរដ្ឋអាមេរិក"

គ-ឡាច ធី ចំនួន ០៣ជី "បីជី" មាស

ឃ-ធន់ បូ ចំនួន ០៥ជី "ប្រាំជី" មាស

ង-ម៉ យ មុំ ចំនួន ១២០ ដុល្លា "មួយរយម្ភៃដុល្លាសហរដ្ឋអាមេរិក"

ច-ភឿន យុក ចំនួន ១០០ ដុល្លា "មួយរយដុល្លាសហរដ្ឋអាមេរិក"

គឺជាបន្ទុករបស់អ្នកស្រី ឆ អ ក៏ប៉ុន្តែដីមួយកន្លែងស្ថិតនៅភូមិស្រះស្រង់ខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប មានទំហំ ២០ម គុណនឹង ១០០ម ជាទ្រព្យផ្ទាល់ខ្លួនរបស់ឈ្មោះ ម ម ដែលមានព្រំប្រទល់ខាងជើងទល់ផ្លូវស្រះស្រង់ខាងត្បូងទល់ដី ម ៩ ខាងកើតទល់ ឈ ហ ខាងលិចទល់ដី ម ៩ "ជាដីអប្បរា" ត្រូវប្រគល់អោយចុងចម្លើយឈ្មោះ ឆ អ ដើម្បីទុកលក់សងបំណុលរួមទាំងអស់ តាមការព្រមព្រៀងរបស់គូភាគី ។

៨-សំរេចប្រគល់ដីមួយកន្លែង ស្ថិតនៅភូមិស្រះស្រង់ខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប មានទំហំ ៤០ម គុណនឹង ៤០ម ដែលមានព្រំប្រទល់ខាងជើងទល់ដី ឆ អ ខាងត្បូងទល់ដី ផ្ ក ខាងកើតទល់ ត ឃ ខាងលិចទល់ ទ រ "ជាដីអប្បរា" ជាទ្រព្យសម្បត្តិផ្ទាល់របស់ចុងចម្លើយឈ្មោះ ឆ អ អោយទៅចុងចម្លើយឈ្មោះ ឆ អ គ្រប់គ្រងជាកម្មសិទ្ធិតាមការព្រមព្រៀងរបស់គូភាគី ។

៩-សំរេចឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹង ១.៨០០រ៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រ៛០០ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រ៛០០ បូករួម ៧.០០០រ៛០០ ។ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រ៛០០ ដែលដើមចោទបានបង់ទុករួចហើយ ។ កាលបើហួសឧទ្ធរណ៍ត្រូវបង្គាប់អោយចុងចម្លើយសងប្រាក់ ៧.០០០រៀលនេះអោយទៅដើមចោទវិញ ។

១០-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់ ០២ខែ គិតពីថ្ងៃនេះតទៅ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជំរះ**

[redacted] [redacted]

CS CamScanner